**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ: ១៧០៤២០ [illegible]

រាជធានីភ្នំពេញ ថ្ងៃទី...១៧...ខែវិច្ឆិកា ឆ្នាំ២០១៧

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវអភិបាល និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត**

**__កម្មវត្ថុ__** ÷ ស្តីពីការអនុវត្តសាលដីការបស់តុលាការកំពូលស្តីពីការរំលាយគណបក្សសង្គ្រោះជាតិ។

**__យោង__** ÷ - ច្បាប់ស្តីពីគណបក្សនយោបាយ

- សាលដីកាលេខ៣៤០ (ធ) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់តុលាការកំពូល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រសួងមហាផ្ទៃ សូមជម្រាបជូន **ឯកឧត្តម លោកជំទាវអភិបាល និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត** ជ្រាបថា តុលាការកំពូលបានសម្រេចរំលាយគណបក្សសង្គ្រោះជាតិ និងបានហាមឃាត់ការធ្វើសកម្មភាពនយោបាយរបស់ថ្នាក់ដឹកនាំនៃគណបក្សនេះ ចំនួន១១៨ (មួយរយដប់ប្រាំបី) នាក់ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីគណបក្សនយោបាយ តាមរយៈសាលដីកាលេខ៣៤០ (ធ) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧។

ដើម្បីអនុវត្តសាលដីការបស់តុលាការកំពូល ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដល់រដ្ឋបាលរាជធានី ខេត្ត និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដូចខាងក្រោម៖

–ត្រូវផ្សព្វផ្សាយ អប់រំ ណែនាំដល់ប្រជាពលរដ្ឋ ដើម្បីអនុវត្តនូវសាលដីការបស់តុលាការកំពូលដែលបានរំលាយគណបក្សសង្គ្រោះជាតិ។

–ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រង ការរក្សាការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈក្នុងរាជធានី ខេត្តនីមួយៗ។

–ចំពោះស្លាកការបស់គណបក្សសង្គ្រោះជាតិដែលមាននៅក្នុងរាជធានី ខេត្តនីមួយៗ ត្រូវណែនាំឱ្យទម្លាក់ស្លាកសញ្ញា បដា ពាក្យស្លោកផ្សេងៗ... ហើយមិនត្រូវធ្វើសកម្មភាពនានាពាក់ព័ន្ធនឹងគណបក្សសង្គ្រោះជាតិដែលត្រូវបានរំលាយដោយតុលាការកំពូលរួចហើយ។

–ត្រូវណែនាំដល់ម្ចាស់លំនៅឋាន អគារ សំណង់នានា ឱ្យធ្វើការដកចេញនូវស្លាកសញ្ញានានារបស់អតីតគណបក្សសង្គ្រោះជាតិពីលំនៅឋាន អគារ សំណង់នានារបស់ខ្លួនជាបន្ទាន់។ ចំពោះស្លាកសញ្ញានៅតាមទីសាធារណៈ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់ចែងការរុះរើចេញជាបន្ទាន់។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវអភិបាល និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត** ចាត់ចែងអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាព។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ